ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..០០៤.....សហវ.......

# សារាចរ
## ស្ដីពី
## ការអនុវត្តប្រកាសលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ និងបទបញ្ញត្តិវិសោធនកម្មពាក់ព័ន្ធ

ដើម្បីធានាសមធម៌ ស័ក្តិសិទ្ធភាព ប្រសិទ្ធភាព សង្គតិភាព តម្លាភាព និងគណនេយ្យភាព ក្នុងការអនុវត្តប្រកាសលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ ស្ដីពីការកំណត់គោលការណ៍ យន្តការ នីតិវិធី និងការត្រួតពិនិត្យសម្រាប់ការផ្ដល់ការលើកទឹកចិត្ត ដោយប្រើប្រាស់ប្រាក់រង្វាន់របស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងបទបញ្ញត្តិវិសោធនកម្មពាក់ព័ន្ធ, អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន វិទ្យាស្ថាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទាំងអស់ ត្រូវអនុវត្តតាមគោលការណ៍ណែនាំ ដែលត្រូវបានកំណត់ដូចតទៅ÷

### ក. ការរៀបចំផែនការលើកទឹកចិត្ត

គណៈកម្មាធិការវាយតម្លៃសមិទ្ធកម្មនិងផ្ដល់ការលើកទឹកចិត្ត នៃអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន វិទ្យាស្ថាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលសរសេរកាត់ថា **គ.ស.ល** នៃអង្គភាព ត្រូវរៀបចំសំណើផែនការលើកទឹកចិត្តប្រចាំឆ្នាំ ផ្ញើជូនគណៈកម្មាធិការវាយតម្លៃសមិទ្ធកម្មនិងផ្ដល់ការលើកទឹកចិត្ត នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលសរសេរកាត់ថា **គ.ស.ល** នៃ កសហវ. តាមរយៈអគ្គលេខាធិការដ្ឋាន កសហវ. និងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលសរសេរកាត់ថា **អ.គ.ហ** ឱ្យបានយ៉ាងយូរមុនដំណាច់ខែតុលា មុនឆ្នាំអនុវត្ត ដើម្បីពិនិត្យ ផ្ដល់យោបល់កែលម្អ និងបូកសរុបដាក់ជូន **គ.ស.ល** នៃ កសហវ. ពិនិត្យនិងសម្រេចដាក់ឱ្យអនុវត្ត។

ផែនការលើកទឹកចិត្ត រួមមានដូចតទៅ÷

- ផែនការសកម្មភាពសម្រាប់ទទួលប្រាក់ឧបត្ថម្ភមុខងារ
- លក្ខខណ្ឌយោងនៃសមាសភាពគម្រោង/ក្រុមការងារទទួលប្រាក់ឧបត្ថម្ភមុខងារ
- គម្រោងថវិកាលើកទឹកចិត្ត។

ផែនការលើកទឹកចិត្តនេះ ត្រូវអនុវត្តផងដែរចំពោះគ្រប់អង្គភាពមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

### ក១. ផែនការសកម្មភាពសម្រាប់ទទួលប្រាក់ឧបត្ថម្ភមុខងារ

**គ.ស.ល** នៃអង្គភាព ត្រូវរៀបចំ និងបូកសរុបផែនការសកម្មភាពប្រចាំឆ្នាំ សម្រាប់ទទួលប្រាក់ឧបត្ថម្ភមុខងារ។ ផែនការសកម្មភាពសម្រាប់ទទួលប្រាក់ឧបត្ថម្ភមុខងារ គឺជាផែនការសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬផែនការសកម្មភាពក្រៅការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ផែនការសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវរៀបចំដោយអនុលោមតាមសារាចររបស់រាជរដ្ឋាភិបាលលេខ ០៩ សរ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីវិធាននិងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ក្រៅពីការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អង្គភាពនីមួយៗ អាចរៀបចំសំណើផែនការសកម្មភាពសម្រាប់ទទួលប្រាក់ឧបត្ថម្ភមុខងារ ក្នុងករណីមាន ១-ការងារសិក្សាស្រាវជ្រាវ, ២-ការងាររៀបចំច្បាប់និងគោលនយោបាយ, ៣-ការងារជំនាញចាំបាច់, ៤-ការងារចូលរួមអនុវត្តគម្រោងនិងក្រុមការងារ និង ៥-ការងារផ្តល់មតិប្រឹក្សាច្បាប់ ទៅតាមនិយមន័យនិងលក្ខណវិនិច្ឆ័យដូចតទៅ÷

១- **ការងារសិក្សាស្រាវជ្រាវ÷** សំដៅដល់ការងារសិក្សាស្រាវជ្រាវលើប្រធានបទជាក់លាក់និងចាំបាច់ពាក់ព័ន្ធវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់រៀបចំគោលនយោបាយថ្មី ឬ កែសម្រួលលើគោលនយោបាយកំពុងអនុវត្ត។ លទ្ធផលនៃការអនុវត្តការងារសិក្សាស្រាវជ្រាវ ត្រូវមានជារបាយការណ៍ ឬឯកសារលទ្ធផលសិក្សាស្រាវជ្រាវលម្អិតមួយ ដែលត្រូវគោរពជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

២- **ការងាររៀបចំច្បាប់និងគោលនយោបាយ÷** សំដៅដល់ការងារតាក់តែងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមិនមែនជាលិខិតបទដ្ឋានពាក់ព័ន្ធនឹងការតែងតាំង ការបង្កើតក្រុមការងារ គណៈកម្មាធិការ ឬគណៈកម្មការណាមួយឡើយ។ រីឯការងាររៀបចំគោលនយោបាយ សំដៅដល់ការងាររៀបចំគោលនយោបាយសម្រាប់ដាក់ឱ្យអនុវត្តដោយរាជរដ្ឋាភិបាល។ លទ្ធផលនៃការអនុវត្តការងាររៀបចំច្បាប់និងគោលនយោបាយ ត្រូវមានសេចក្តីព្រាងលិខិតបទដ្ឋាន ឬសេចក្តីព្រាងឯកសារគោលនយោបាយ ដែលត្រូវគោរពជូនថ្នាក់ដឹកនាំពិនិត្យនិងសម្រេចដាក់ឱ្យប្រើប្រាស់ ឬដាក់ឱ្យអនុវត្ត។

៣- **ការងារជំនាញចាំបាច់÷** សំដៅដល់ការអនុវត្តការងារដែលត្រូវការជំនាញចាំបាច់នានា ដែលមានលទ្ធផលអាចវាស់វែងបាន ដែលមិនមែនជាការងារសិក្សាស្រាវជ្រាវ ឬការងាររៀបចំច្បាប់និងគោលនយោបាយ ទៅតាមការសម្រេចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ លទ្ធផលនៃការអនុវត្តការងារជំនាញចាំបាច់ ត្រូវមានជាលទ្ធផលជាក់ស្តែងនៃការអនុវត្តការងារ ដែលត្រូវគោរពរាយការណ៍ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៤- **ការងារចូលរួមអនុវត្តគម្រោងនិងក្រុមការងារ÷** សំដៅដល់ការអនុវត្តការងារចាំបាច់ ក្នុងក្របខ័ណ្ឌនៃក្រុមការងារ គណៈកម្មាធិការ ឬគណៈកម្មការណាមួយ ដែលត្រូវបានសម្រេចបង្កើតដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ លទ្ធផលនៃការងារចូលរួមក្រុមការងារ ត្រូវមានជាលទ្ធផលជាក់លាក់នៃការអនុវត្តមុខងារនិងភារកិច្ចដែលមានកំណត់ក្នុងលិខិតបទដ្ឋានបង្កើតក្រុមការងារ គណៈកម្មការ ឬគណៈកម្មាធិការ ដែលត្រូវទទួលខុសត្រូវដោយសមាសភាពដែលស្នើសុំប្រាក់ឧបត្ថម្ភមុខងារ។

៥- **ការងារផ្តល់មតិប្រឹក្សាច្បាប់÷** សំដៅដល់ការងារផ្តល់មតិយោបល់ដោយលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម លើទិដ្ឋភាពច្បាប់នៃសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត ដែលរៀបចំដោយអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ លទ្ធផលនៃការអនុវត្តការងារផ្តល់មតិប្រឹក្សាច្បាប់ ត្រូវមានមតិប្រឹក្សាច្បាប់ដែលផ្តល់ជូនអង្គភាពស្នើសុំ។

សំណើផែនការសកម្មភាពសម្រាប់ទទួលប្រាក់ឧបត្ថម្ភមុខងារ ទាំងការងារកែទម្រង់ និងក្រៅការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវរៀបចំតាមគំរូក្នុង**ឧបសម្ព័ន្ធ “ក១.១”**, ឧបសម្ព័ន្ធ**“ក១.២”** និង ឧបសម្ព័ន្ធ **“ក១.៣”**។

**ក២. លក្ខខណ្ឌយោងនៃសមាសភាពគម្រោង/ក្រុមការងារទទួលប្រាក់ឧបត្ថម្ភមុខងារ**

**គ.ស.ល** នៃអង្គភាព ត្រូវកំណត់លក្ខខណ្ឌយោងរបស់សមាសភាពគម្រោង ឬក្រុមការងារនីមួយៗ ដែលត្រូវទទួលប្រាក់ឧបត្ថម្ភមុខងារ ឱ្យបានច្បាស់លាស់ ទៅតាមទម្រង់ដូចមានកំណត់ក្នុង**ឧបសម្ព័ន្ធ “ក២”**។

**ក៣. គម្រោងថវិកាលើកទឹកចិត្ត**

**គ.ស.ល** នៃអង្គភាព ត្រូវរៀបចំគម្រោងថវិកាសម្រាប់អនុវត្តផែនការលើកទឹកចិត្តប្រចាំឆ្នាំ របស់អង្គភាព ដោយរួមបញ្ចូលគ្រប់ប្រភេទនៃប្រាក់ឧបត្ថម្ភ ទៅតាមទម្រង់ដែលមានកំណត់ក្នុង**ឧបសម្ព័ន្ធ “ក៣”**។

**ខ. ការអនុវត្តផែនការលើកទឹកចិត្ត**

អង្គភាពនីមួយៗត្រូវអនុវត្តផែនការលើកទឹកចិត្ត ដោយត្រូវពង្រឹងការគ្រប់គ្រងវត្តមាននិងគុណភាពការងាររបស់មន្ត្រីក្រោមឱវាទ សម្រាប់ទទួលប្រាក់ឧបត្ថម្ភជីវភាព និងត្រូវសម្រេចឱ្យបាននូវគោលដៅសូចនាករនៃសកម្មភាពនីមួយៗ ដូចមានកំណត់ក្នុងផែនការសកម្មភាពទទួលប្រាក់ឧបត្ថម្ភមុខងារ ដែលត្រូវបានដាក់ឱ្យអនុវត្តដោយ **គ.ស.ល** នៃ កសហវ.។

**គ.ស.ល** នៃអង្គភាព ត្រូវផ្តល់របាយការណ៍សមិទ្ធកម្មនៃការអនុវត្តផែនការលើកទឹកចិត្ត ជូន **គ.ស.ល** នៃ កសហវ. តាមរយៈអគ្គលេខាធិការដ្ឋាន កសហវ. និង **អ.គ.ហ**ដូចតទៅ÷

- របាយការណ៍សមិទ្ធកម្មនៃការអនុវត្តផែនការសកម្មភាពសម្រាប់ទទួលប្រាក់ឧបត្ថម្ភមុខងារ ប្រចាំត្រីមាស ទាំងការងារកែទម្រង់ និងក្រៅការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវផ្ញើជូននៅសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ តាមទម្រង់ដូចមានក្នុង**ឧបសម្ព័ន្ធ “១១.១”** និង **ឧបសម្ព័ន្ធ “១១.២”**
- របាយការណ៍សមិទ្ធកម្មនៃការអនុវត្តផែនការលើកទឹកចិត្តប្រចាំឆ្នាំ ត្រូវផ្ញើជូននៅសប្តាហ៍ទី២ នៃខែមករា នៃឆ្នាំបន្ទាប់ តាមទម្រង់ដូចមានកំណត់ក្នុង**ឧបសម្ព័ន្ធ “១២.១”**, **ឧបសម្ព័ន្ធ “១២.២”** និង **ឧបសម្ព័ន្ធ “១២.៣”**។

**គ.ស.ល** នៃអង្គភាព ត្រូវរៀបចំវាយតម្លៃសមិទ្ធកម្មមន្ត្រីដែលត្រូវទទួលប្រាក់ឧបត្ថម្ភជីវភាព និងប្រាក់ឧបត្ថម្ភមុខងារ ជាប្រចាំត្រីមាស ទៅតាមទម្រង់ដូចមានក្នុង**ឧបសម្ព័ន្ធ “១៣”** និង**ឧបសម្ព័ន្ធ “១៤”**។ ឯកសារវាយតម្លៃសមិទ្ធកម្មមន្ត្រីនីមួយៗ ពុំតម្រូវឱ្យផ្ញើមក **គ.ស.ល** នៃ កសហវ. ឡើយ។

សម្រាប់ប្រាក់ឧបត្ថម្ភជីវភាព **គ.ស.ល** នៃអង្គភាព ត្រូវរៀបចំ “របាយការណ៍វាយតម្លៃសមិទ្ធកម្មមន្ត្រីទទួលប្រាក់ឧបត្ថម្ភជីវភាព ប្រចាំត្រីមាស” ផ្ញើជូន **គ.ស.ល** នៃ កសហវ. តាមរយៈអគ្គលេខាធិការដ្ឋាន កសហវ. នៅសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ ទៅតាមទម្រង់ដូចមានក្នុង**ឧបសម្ព័ន្ធ “១៥”**។

**គ.ស.ល** នៃអង្គភាព ត្រូវរៀបចំ “បញ្ជីសម្រង់អវត្តមានមន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យា និងការផ្លាស់ប្តូរស្ថានភាពរដ្ឋបាលប្រចាំខែ” ដោយស្រង់តែឈ្មោះមន្ត្រីដែលអវត្តមាន ជូន **គ.ស.ល** នៃ កសហវ. តាមរយៈអគ្គលេខាធិការដ្ឋាន កសហវ. យ៉ាងយូរត្រឹមសប្តាហ៍ទី ១ នៃខែបន្ទាប់ ទៅតាមទម្រង់ដូចមានក្នុង**ឧបសម្ព័ន្ធ “១៦”**។

ក្នុងករណីមានបម្រែបម្រួលសមាសភាពមន្ត្រីទទួលប្រាក់ឧបត្ថម្ភណាមួយ, **គ.ស.ល** នៃអង្គភាពត្រូវរៀបចំ “បញ្ជីសម្រង់បម្រែបម្រួលសមាសភាពមន្ត្រីទទួលប្រាក់ឧបត្ថម្ភ” តាមទម្រង់ដូចមានក្នុង**ឧបសម្ព័ន្ធ “១៧”** រួចផ្ញើមក អគ្គលេខាធិការដ្ឋាន កសហវ. និង **អ.គ.ហ** យ៉ាងយូរត្រឹមសប្តាហ៍ទី១ នៃខែបន្ទាប់ ដើម្បីរៀបចំគោរពជូន **គ.ស.ល** នៃ កសហវ. ពិនិត្យនិងសម្រេច។

**គ. ការត្រួតពិនិត្យនិងវាយតម្លៃសមិទ្ធកម្ម**

អង្គភាពទទួលប្រាក់ឧបត្ថម្ភ ត្រូវទទួលរងការត្រួតពិនិត្យនិងវាយតម្លៃសមិទ្ធកម្មជាប្រចាំត្រីមាស ដោយ÷

- អគ្គលេខាធិការដ្ឋាន កសហវ. ចំពោះប្រាក់ឧបត្ថម្ភជីវភាព និងប្រាក់ឧបត្ថម្ភមុខងារក្រៅការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- **អ.គ.ហ** ចំពោះប្រាក់ឧបត្ថម្ភមុខងារការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ការត្រួតពិនិត្យនិងវាយតម្លៃសមិទ្ធកម្មសម្រាប់ប្រាក់ឧបត្ថម្ភមុខងារ អនុវត្តតាមការត្រួតពិនិត្យលើរបាយការណ៍សមិទ្ធកម្មនៃការអនុវត្តផែនការសកម្មភាពទទួលប្រាក់ឧបត្ថម្ភមុខងាររបស់អង្គភាព។ ក្នុងករណីចាំបាច់ អង្គភាពទទួលប្រាក់ឧបត្ថម្ភមុខងារ អាចត្រូវបានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សា ឬធ្វើបទបង្ហាញអំពីវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព។

លទ្ធផលនៃការត្រួតពិនិត្យនិងវាយតម្លៃសមិទ្ធកម្មសម្រាប់ប្រាក់ឧបត្ថម្ភមុខងារ ដូចមានកំណត់ក្នុង**ឧបសម្ព័ន្ធ “គ១”** និង **ឧបសម្ព័ន្ធ “គ២”** ត្រូវបញ្ជូនទៅអគ្គលេខាធិការដ្ឋាន កសហវ. ដើម្បីបើកផ្តល់ប្រាក់ឧបត្ថម្ភ។

ការអនុវត្តផែនការលើកទឹកចិត្តប្រចាំឆ្នាំ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវត្រួតពិនិត្យនិងវាយតម្លៃក្នុងកិច្ចប្រជុំរបស់ **គ.ស.ល** នៃ កសហវ.។ អគ្គលេខាធិការដ្ឋាន កសហវ. ត្រូវសម្របសម្រួលរៀបចំកិច្ចប្រជុំនេះ។

## ឃ. ការបើកផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្ត

### ឃ១. ការបើកផ្តល់ប្រាក់ឧបត្ថម្ភជីវភាព

នាយកដ្ឋានបុគ្គលិក នៃអគ្គលេខាធិការដ្ឋាន កសហវ. ត្រូវរៀបចំសំណើបើកផ្តល់ប្រាក់ឧបត្ថម្ភជីវភាពប្រចាំខែ ជូនមន្ត្រីដែលត្រូវទទួលប្រាក់ឧបត្ថម្ភជីវភាព ដូចមានរាយនាមក្នុងគម្រោងថវិកាលើកទឹកចិត្តប្រចាំឆ្នាំ នៃគ្រប់អង្គភាព ជូន **គ.ស.ល** នៃ កសហវ. ពិនិត្យ និងសម្រេចបើកផ្តល់។ មានតែមន្ត្រីដែលទទួលបានកម្រិតពិន្ទុសមិទ្ធកម្មត្រីមាសមុនចាប់ពី ៥០/១០០ ប៉ុណ្ណោះ ទើបអាចទទួលបានប្រាក់ឧបត្ថម្ភជីវភាព។

ក្នុងករណីមានបម្រែបម្រួលសមាសភាពមន្ត្រីទទួលប្រាក់ឧបត្ថម្ភជីវភាព នាយកដ្ឋានបុគ្គលិក នៃអគ្គលេខាធិការដ្ឋាន កសហវ. ត្រូវពិនិត្យនិងលើកយោបល់ជូន **គ.ស.ល** នៃ កសហវ. ពិនិត្យនិងសម្រេច។ សំណើសុំរំលឹកប្រាក់ឧបត្ថម្ភជីវភាពលើសពី ១ (មួយ) ខែ នឹងមិនត្រូវរៀបចំជូនឡើយ។

### ឃ២. ការបើកផ្តល់ប្រាក់ឧបត្ថម្ភមុខងារ

ប្រាក់ឧបត្ថម្ភមុខងារ ត្រូវបើកផ្តល់ទៅតាមលទ្ធផលនៃការត្រួតពិនិត្យនិងវាយតម្លៃសមិទ្ធកម្មប្រចាំត្រីមាស លើការអនុវត្តផែនការសកម្មភាពទទួលប្រាក់ឧបត្ថម្ភមុខងារ ទៅតាមគោលការណ៍កំណត់ដូចតទៅ÷

- ពិន្ទុពី ៨៦ ដល់ ១០០ ទទួលបានប្រាក់ឧបត្ថម្ភមុខងារ ១០០%
- ពិន្ទុពី ៧១ ដល់ត្រឹម ៨៥ ទទួលបានប្រាក់ឧបត្ថម្ភមុខងារ ៨០%
- ពិន្ទុពី ៦១ ដល់ត្រឹម ៧០ ទទួលបានប្រាក់ឧបត្ថម្ភមុខងារ ៥០%
- ពិន្ទុក្រោម ៦០ ពុំទទួលបានប្រាក់ឧបត្ថម្ភមុខងារទេ។

នាយកដ្ឋានបុគ្គលិក នៃអគ្គលេខាធិការដ្ឋាន កសហវ. ត្រូវរៀបចំសំណើបើកផ្តល់ប្រាក់ឧបត្ថម្ភមុខងារប្រចាំខែ តាមកម្រិតទឹកប្រាក់កំណត់ក្នុងគោលការណ៍ខាងលើ នៅក្នុងខែនីមួយៗ នៃត្រីមាសបន្ទាប់ ជូនមន្ត្រីដែលត្រូវទទួលប្រាក់ឧបត្ថម្ភមុខងារ ដូចមានរាយនាមក្នុងគម្រោងថវិកាលើកទឹកចិត្តប្រចាំឆ្នាំ នៃអង្គភាព ជូន **គ.ស.ល** នៃ កសហវ. ពិនិត្យនិងសម្រេចបើកផ្តល់។

ក្នុងករណីមានបម្រែបម្រួលសមាសភាពមន្ត្រីទទួលប្រាក់ឧបត្ថម្ភមុខងារ, នាយកដ្ឋានបុគ្គលិក នៃអគ្គលេខាធិការដ្ឋាន កសហវ. ត្រូវពិនិត្យនិងលើកយោបល់ជូន **គ.ស.ល** នៃ កសហវ. ពិនិត្យនិងសម្រេច។

ប្រាក់ឧបត្ថម្ភមុខងារថ្នាក់ដឹកនាំ ទីប្រឹក្សា និងជំនួយការថ្នាក់ដឹកនាំ ត្រូវបើកផ្តល់ជាប្រចាំខែ ផ្អែកលើការវាយតម្លៃសមិទ្ធកម្មដោយផ្ទាល់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

### ឃ៣. ករណីអវត្តមាន

ទន្ទឹមនឹងលក្ខខណ្ឌខាងលើ ការបើកផ្តល់ប្រាក់ឧបត្ថម្ភទាំងពីរប្រភេទ ត្រូវផ្អែកលើអវត្តមានរបស់មន្ត្រី តាមគោលការណ៍កំណត់ដូចតទៅ÷

- ករណីអវត្តមានដោយគ្មានច្បាប់អនុញ្ញាត÷
  - ពី ១ថ្ងៃ ដល់ត្រឹម ៥ថ្ងៃ ÷ ប្រាក់ឧបត្ថម្ភទាំងពីរប្រភេទត្រូវកាត់ចេញតាមសមាមាត្រនឹងចំនួនថ្ងៃអវត្តមាន
  - ពី ៦ថ្ងៃឡើងទៅ ÷ ប្រាក់ឧបត្ថម្ភទាំងពីរប្រភេទមិនត្រូវបានបើកផ្តល់ជូនឡើយ។
- ករណីអវត្តមានដោយមានច្បាប់អនុញ្ញាតត្រឹមត្រូវ (ច្បាប់ឈប់រយៈពេលខ្លី និងច្បាប់ឈប់ប្រចាំឆ្នាំ)÷

- ត្រឹម ១៥ថ្ងៃ÷ ទទួលបានប្រាក់ឧបត្ថម្ភទាំង២ប្រភេទ
- ពី ១៦ថ្ងៃ ដល់ត្រឹម ៣០ថ្ងៃ÷ ទទួលបានប្រាក់ឧបត្ថម្ភជីវភាពតែប៉ុណ្ណោះ
- លើសពី ៣០ថ្ងៃ÷ មិនទទួលបានប្រាក់ឧបត្ថម្ភទាំង២ប្រភេទ។

- ករណីអវត្តមានតាមការចាត់តាំងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ÷
  - ត្រឹម ៣ខែ÷ ទទួលបានប្រាក់ឧបត្ថម្ភទាំង ២ប្រភេទ
  - ពី ៣ខែ ដល់ត្រឹម ៦ខែ÷ ទទួលបានប្រាក់ឧបត្ថម្ភជីវភាពតែប៉ុណ្ណោះ
  - លើសពី ៦ខែ÷ មិនទទួលបានប្រាក់ឧបត្ថម្ភទាំង២ប្រភេទ។
- ករណីលំហែមាតុភាព ជម្ងឺ ឬ គ្រោះថ្នាក់ដោយសារការបំពេញភារកិច្ច÷
  - ត្រឹម ៣ខែ÷ ទទួលបានប្រាក់ឧបត្ថម្ភទាំង២ប្រភេទ
  - លើសពី ៣ខែ ÷ ទទួលបានប្រាក់ឧបត្ថម្ភជីវភាពតែប៉ុណ្ណោះ។

គោលការណ៍ពាក់ព័ន្ធករណីអវត្តមានខាងលើនេះ អនុវត្តចំពោះតែការផ្តល់ការលើកទឹកចិត្តប៉ុណ្ណោះ ដោយមិនទាន់រាប់បញ្ចូលវិធានការរដ្ឋបាលនានាតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

## ខ. ការគ្រប់គ្រងប្រាក់រង្វាន់

ដើម្បីធានាប្រសិទ្ធភាព និងគណនេយ្យភាព នៃការគ្រប់គ្រងប្រាក់រង្វាន់ អគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវរៀបចំរបាយការណ៍សមតុល្យនៃគណនីប្រាក់រង្វាន់ប្រចាំខែ នៅក្នុងសប្តាហ៍ទី១ នៃខែបន្ទាប់, ប្រចាំត្រីមាស នៅក្នុងសប្តាហ៍ទី២ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំ នៅក្នុងសប្តាហ៍ទី២ នៃឆ្នាំបន្ទាប់ ទៅតាមទម្រង់ដែលកំណត់ក្នុង**ឧបសម្ព័ន្ធ "ង១"** មក **គ.ស.ល** នៃ កសហវ. តាមរយៈអគ្គលេខាធិការដ្ឋាន កសហវ. និង **អ.គ.ហ**។

## ច. សេចក្តីណែនាំបន្ថែមសម្រាប់អង្គភាពប្រមូលចំណូល

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ និងអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ត្រូវរៀបចំកែសម្រួលការបែងចែកប្រាក់រង្វាន់របស់ខ្លួន ដោយអនុលោមតាមគោលការណ៍ នីតិវិធី យន្តការ និងការត្រួតពិនិត្យការផ្តល់ការលើកទឹកចិត្ត តាមរយៈការកែសម្រួលលើប្រកាស និងសេចក្តីណែនាំជាធរមាន ឱ្យបានរួចរាល់សម្រាប់ការចាប់ផ្តើមអនុវត្តចាប់ពីខែកក្កដា ឆ្នាំ២០១៧ តទៅ ដោយត្រូវបានអនុញ្ញាតឱ្យកំណត់សន្ទស្សន៍ និងតម្លៃឯកតានៃសន្ទស្សន៍ដោយខ្លួនឯង និងដោយផ្អែកលើប្រាក់រង្វាន់របស់ខ្លួន ដែលបានកំណត់។

## ឆ. នីតិវិធីបណ្តឹង

មន្ត្រីដែលមិនពេញចិត្តឬជំទាស់នឹងការវាយតម្លៃសមិទ្ធកម្ម ការត្រួតពិនិត្យសមិទ្ធកម្ម ឬ ការសម្រេចនានាពាក់ព័ន្ធនឹងការផ្តល់ការលើកទឹកចិត្ត អាចដាក់ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរមក **គ.ស.ល** នៃអង្គភាព ដែលត្រូវចេញសេចក្តីសម្រេចក្នុងរយៈពេល ១៥ថ្ងៃ ក្រោយពីថ្ងៃទទួលពាក្យបណ្តឹង និងឯកសារពាក់ព័ន្ធគ្រប់គ្រាន់។

ក្នុងករណីមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់ **គ.ស.ល** នៃអង្គភាពរបស់ខ្លួន សាមីមន្ត្រីអាចដាក់ពាក្យបណ្តឹងមក **គ.ស.ល** នៃ កសហវ. ដែលត្រូវចេញសេចក្តីសម្រេចក្នុងរយៈពេល ១ខែ ក្រោយពីថ្ងៃទទួលពាក្យបណ្តឹង និងឯកសារពាក់ព័ន្ធគ្រប់គ្រាន់។

## ជ. នីតិវិធីសវនកម្មផ្ទៃក្នុង

សមិទ្ធកម្មនៃផែនការលើកទឹកចិត្តរបស់អង្គភាពនីមួយៗ ត្រូវទទួលរងសវនកម្មនៅរៀងរាល់ដំណាច់ឆ្នាំដោយអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្នុងស្មារតីនេះ គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវផ្តល់កិច្ចសហការពេញលេញ ជូនអគ្គ-នាយកដ្ឋានសវនកម្មផ្ទៃក្នុង ដើម្បីអនុញ្ញាតឱ្យការធ្វើសវនកម្មចំពោះសមិទ្ធកម្មលើផែនការលើកទឹកចិត្ត ប្រចាំឆ្នាំនីមួយៗ អាចប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

ទទួលបានសារាចរនេះ អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន វិទ្យាស្ថាន និងអង្គភាពទាំងអស់ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់ ព្រមទាំងត្រូវរាយការណ៍អំពីលទ្ធផលនៃការអនុវត្ត ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុវិញ។

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៧

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
អគ្គនាយកដ្ឋាន..................

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធ "ក១.១" នៃសារាចរលេខ០០៤.សហវ ចុះថ្ងៃទី១២ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការអនុវត្តប្រកាសលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ និងបទប្បញ្ញត្តិវិសោធនកម្មពាក់ព័ន្ធ

## ផែនការសកម្មភាពសម្រាប់ទទួលប្រាក់ឧបត្ថម្ភមុខងារ ប្រចាំឆ្នាំ.......

### ១. ផែនការសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ:

រយៈពេលអនុវត្ត÷.......ខែ ពី..... ដល់.....

| ផ្នែកគោលបំណង | ចង្កោមសកម្មភាព | | | សកម្មភាព | | | គោលដៅសូចនាករប្រចាំត្រីមាស ក្នុងឆ្នាំ.... | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | បរិយាយ | ទម្ងន់ CAP3 | ទម្ងន់ អង្គភាព | បរិយាយ | គោលដៅសូចនាករឆ្នាំ | ទម្ងន់ | ខ្នាតរង្វាស់ | ត្រីមាសទី១ | | | ត្រីមាសទី២ | | | ត្រីមាសទី៣ | | | ត្រីមាសទី៤ | | |
| | | | | | | | | ទម្ងន់ | សូចនាករ | គោលដៅ | ទម្ងន់ | សូចនាករ | គោលដៅ | ទម្ងន់ | សូចនាករ | គោលដៅ | ទម្ងន់ | សូចនាករ | គោលដៅ |
| សរុបទម្ងន់ | | | ១ | | | ១ | | ១ | | | ១ | | | ១ | | | ១ | | |
| ផ្នែកទី១÷បន្តពង្រឹងតាមគណនេយ្យភាពហិរញ្ញវត្ថុ | | | | | | | | | | | | | | | | | | | |
| គ/បទី១១÷ បន្តពង្រឹងការគ្រប់គ្រងចំណូលនិងការអនុវត្តផែនការប្រមូលចំណូល | ១១.១ ពង្រឹងការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម | | | ១១.១.១ | | | | | | | | | | | | | | | |
| | | | | ១១.១.២ | | | | | | | | | | | | | | | |
| | ១១.២ បន្តកែលម្អគោលនយោបាយនិងរដ្ឋបាលគយ ពន្ធដារ និងចំណូលមិនមែនសារពើពន្ធ | | | ១១.២.១ | | | | | | | | | | | | | | | |
| | | | | ១១.២.២ | | | | | | | | | | | | | | | |
| ផ្នែកទី..÷ | | | | | | | | | | | | | | | | | | | |
| គ/បទី..÷ | .. . .. | | | .. . .. . .. | | | | | | | | | | | | | | | |
| | | | | .. . .. . .. | | | | | | | | | | | | | | | |
| | .. . .. | | | .. . .. . .. | | | | | | | | | | | | | | | |
| | | | | .. . .. . .. | | | | | | | | | | | | | | | |

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១...
ប្រធាន គ.ស.ល នៃអគ្គនាយកដ្ឋាន......
អគ្គនាយក

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋាន..................**

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធ "ក១.២" នៃសារាចរលេខ..០០៤..សហវ ចុះថ្ងៃទី..០២..ខែ..កុម្ភៈ..ឆ្នាំ២០១៧ ស្ដីពីការអនុវត្តប្រកាសលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ និងបទប្បញ្ញត្តិវិសោធនកម្មពាក់ព័ន្ធ

**ផែនការសកម្មភាពសម្រាប់ទទួលប្រាក់ឧបត្ថម្ភមុខងារ ប្រចាំឆ្នាំ.......**

**២. ផែនការសកម្មភាពក្រៅកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ:**

**២.១ គម្រោង...** *(ការងារសិក្សាស្រាវជ្រាវ/ការងាររៀបចំច្បាប់និងគោលនយោបាយ/ការងារជំនាញចាំបាច់/ការងារចូលរួមអនុវត្តគម្រោងនិងក្រុមការងារ/ការងារផ្ដល់មតិប្រឹក្សាច្បាប់)*

រយៈពេលអនុវត្ត÷.......ខែ ពី..... ដល់.....

| សកម្មភាព | គោលដៅសូចនាករឆ្នាំ | ទម្ងន់ | ខ្នាតរង្វាស់ | ត្រីមាសទី១ | | | ត្រីមាសទី២ | | | ត្រីមាសទី៣ | | | ត្រីមាសទី៤ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ទម្ងន់ | សូចនាករ | គោលដៅ | ទម្ងន់ | សូចនាករ | គោលដៅ | ទម្ងន់ | សូចនាករ | គោលដៅ | ទម្ងន់ | សូចនាករ | គោលដៅ |
| សរុបទម្ងន់ | | ១ | | ១ | | | ១ | | | ១ | | | ១ | | |
| **២.១ គម្រោង...÷** *(គោលដៅនៃគម្រោង)...* ត្រូវបាន...។ | | | | | | | | | | | | | | | |
| ២.១.១ | | | | | | | | | | | | | | | |
| ២.១.២ | | | | | | | | | | | | | | | |
| ២.១.៣ | | | | | | | | | | | | | | | |
| ២.១.៤ | | | | | | | | | | | | | | | |

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១...
**ប្រធាន គ.ស.ល នៃអគ្គនាយកដ្ឋាន......**
**អគ្គនាយក**

ឧបសម្ព័ន្ធ "ក១.៣" នៃសារាចរលេខ០០៤ សហវ ចុះថ្ងៃទី១២ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការអនុវត្តប្រកាសលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ និងបទប្បញ្ញត្តិវិសោធនកម្មពាក់ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋាន..................**

## ឧបសម្ព័ន្ធនៃផែនការសកម្មភាពសម្រាប់ទទួលប្រាក់ឧបត្ថម្ភមុខងារ ប្រចាំឆ្នាំ.......
## តារាងកំណត់កម្រិតពិន្ទុ សម្រាប់ការវាយតម្លៃ

**១. ផែនការសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ:**

រយៈពេលអនុវត្ត÷.......ខែ ពី..... ដល់.....

| សូចនាករ ត្រីមាស | លក្ខខណ្ឌនៃគោលដៅ សម្រាប់កម្រិតពិន្ទុតាមត្រីមាស | | | | ឯកសារផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|
| | ១០០ | ៨០ | ៦០ | ០ | |
| **១១.១.១ .... (ឈ្មោះសូចនាករ)** | | | | | **ខ្នាតរង្វាស់÷.....................** |
| តម១ | | | | | |
| តម២ | | | | | |
| តម៣ | | | | | |
| តម៤ | | | | | |
| **.. . .. . . .... (ឈ្មោះសូចនាករ)** | | | | | **ខ្នាតរង្វាស់÷.....................** |
| តម១ | | | | | |
| តម២ | | | | | |
| តម៣ | | | | | |
| តម៤ | | | | | |

**២. ផែនការសកម្មភាពក្រៅការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ:**

**២.១ គម្រោង...**

រយៈពេលអនុវត្ត÷.......ខែ ពី..... ដល់.....

| សូចនាករ ត្រីមាស | លក្ខខណ្ឌនៃគោលដៅ សម្រាប់កម្រិតពិន្ទុតាមត្រីមាស | | | | ឯកសារផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|
| | ១០០ | ៨០ | ៦០ | ០ | |
| **២.១.១ .... (ឈ្មោះសូចនាករ)** | | | | | **ខ្នាតរង្វាស់÷.....................** |
| តម១ | | | | | |
| តម២ | | | | | |
| តម៣ | | | | | |
| តម៤ | | | | | |

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១...
**ប្រធាន គ.ស.ល នៃអគ្គនាយកដ្ឋាន......**
**អគ្គនាយក**

ឧបសម្ព័ន្ធ "ក២" នៃសារាចរលេខ០០៤ សហវ ចុះថ្ងៃទី០២ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការអនុវត្តប្រកាសលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ និងបទប្បញ្ញត្តិវិសោធនកម្មពាក់ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋាន....**

## លក្ខខណ្ឌយោង

## នៃសមាសភាពគម្រោង/ក្រុមការងារទទួលប្រាក់ឧបត្ថម្ភមុខងារ

លក្ខខណ្ឌយោងនៃសមាសភាពគម្រោង/ក្រុមការងារអនុវត្តផែនការសកម្មភាពសម្រាប់ទទួលប្រាក់ឧបត្ថម្ភមុខងារ របស់អគ្គនាយកដ្ឋាន... ត្រូវបានកំណត់ដូចតទៅ÷

**១. ផែនការសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ:**

| ល.រ | គោត្តនាម នាម | ភេទ | មុខតំណែង | មុខងារក្នុងគម្រោង | សន្ទស្សន៍ | ភារកិច្ចនិងការទទួលខុសត្រូវ |
|---|---|---|---|---|---|---|
| ១. | | | | ប្រធានគម្រោង | | • ទទួលបន្ទុក |
| ២. | | | | អនុប្រធានគម្រោង | | • ទទួលបន្ទុក |
| ៣. | | | | សមាជិក | | • ទទួលបន្ទុក |

**២. ផែនការសកម្មភាពក្រៅការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ:**
**២.១ គម្រោង...**

| ល.រ | គោត្តនាម នាម | ភេទ | មុខតំណែង | មុខងារក្នុងគម្រោង | សន្ទស្សន៍ | ភារកិច្ចនិងការទទួលខុសត្រូវ |
|---|---|---|---|---|---|---|
| ១. | | | | ប្រធានគម្រោង | | • ទទួលបន្ទុក |
| ២. | | | | អនុប្រធានគម្រោង | | • ទទួលបន្ទុក |
| ៣. | | | | សមាជិក | | • ទទួលបន្ទុក |

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១...
**ប្រធាន គ.ស.ល នៃអគ្គនាយកដ្ឋាន......**
**អគ្គនាយក**

ឧបសម្ព័ន្ធ "ក៣" នៃសារាចរលេខ.០០៤.សហវ ចុះថ្ងៃទី១២ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការអនុវត្តប្រកាសលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ និងបទប្បញ្ញត្តិវិសោធនកម្មពាក់ព័ន្ធ

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋាន..................**

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**គម្រោងថវិកាសម្រាប់អនុវត្តផែនការលើកទឹកចិត្ត របស់អគ្គនាយកដ្ឋាន... ប្រចាំឆ្នាំ....**

I. **ប្រាក់ឧបត្ថម្ភជីវភាព**

| ល.រ | គោត្តនាម នាម | ភេទ | តួនាទី | សន្ទស្សន៍ | ប្រាក់ឧបត្ថម្ភប្រចាំខែ | ប្រាក់ឧបត្ថម្ភប្រចាំឆ្នាំ | ធនាគារ | លេខគណនី |
|---|---|---|---|---|---|---|---|---|
| ក.ថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន | | | | | | | | |
| ១ | | | | | | | | |
| ២ | | | | | | | | |
| **ខ.នាយកដ្ឋាន...** | | | | | | | | |
| ៣ | | | | | | | | |
| ៤ | | | | | | | | |
| សរុបប្រាក់ឧបត្ថម្ភជីវភាព | | | | | | | | |

II. **ប្រាក់ឧបត្ថម្ភមុខងារ**

| ល.រ | គោត្តនាម នាម | ភេទ | តួនាទី | សន្ទស្សន៍ | ប្រាក់ឧបត្ថម្ភប្រចាំខែ | ប្រាក់ឧបត្ថម្ភប្រចាំឆ្នាំ | ធនាគារ | លេខគណនី |
|---|---|---|---|---|---|---|---|---|
| ១.ផែនការសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | | | | | | | | |
| ១ | | | | | | | | |
| ២ | | | | | | | | |
| ២.ផែនការសកម្មភាពក្រៅការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | | | | | | | | |
| ២.១.គម្រោង | | | | | | | | |
| ៣ | | | | | | | | |
| ៤ | | | | | | | | |
| សរុបប្រាក់ឧបត្ថម្ភមុខងារ | | | | | | | | |

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១...
**អ្នករៀបចំតារាង**

**បានឃើញ និងឯកភាព**
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១...
**ប្រធាន គ.ស.ល នៃអគ្គនាយកដ្ឋាន......**
**អគ្គនាយក**

ឧបសម្ព័ន្ធ "ខ១.១" នៃសារាចរលេខ០០៤ សហវ ចុះថ្ងៃទី០២ខែកុម្ភៈ ឆ្នាំ២០១៧ ស្ដីពីការអនុវត្តប្រកាសលេខ ៦១៦ សហវ.ប្រក
ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ និងបទប្បញ្ញត្តិវិសោធនកម្មពាក់ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋាន..................**

## របាយការណ៍សមិទ្ធកម្មនៃការអនុវត្តផែនការសកម្មភាពសម្រាប់ទទួលប្រាក់ឧបត្ថម្ភមុខងារ ប្រចាំត្រីមាសទី... ឆ្នាំ.......

### ១. ផែនការសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ:

រយៈពេលអនុវត្ត៖.......ខែ ពី..... ដល់.....

| ផ្នែក គោលបំណង | ចង្កោមសកម្មភាព | | | សកម្មភាព | | | ខ្នាត វាស់ | ត្រីមាសទី... | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | បរិយាយ | ទម្ងន CAP3 | ទម្ងន អង្គភាព | បរិយាយ | គោលដៅសូចនាករឆ្នាំ | ទម្ងន់ | | ទម្ងន់ ១ | សូចនាករ ២ | គោលដៅ ៣ | លទ្ធផល ៤ | ពិន្ទុ ៥ | ពិន្ទុថ្លឹង ៦=៥x១ | អំណះអំណាង |
| សរុបទម្ងន់ | | | ១ | | | ១ | | ១ | | | | | | |
| **ផ្នែកទី១៖បន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា** | | | | | | | | | | | | | | |
| ក/បទី១១៖បន្តពង្រឹង..ចំណូល និង...ផែនការប្រមូលចំណូល | ១១.១ ពង្រឹង.... | | | ១១.១.១ | | | | | | | | | | |
| | | | | ១១.១.២ | | | | | | | | | | |
| | ១១.២ ... | | | ១១.២.១ | | | | | | | | | | |
| | | | | ១១.២.២ | | | | | | | | | | |
| **ផ្នែកទី..៖** | | | | | | | | | | | | | | |
| ក/បទី..៖ | .. . .. | | | .. . .. . .. | | | | | | | | | | |
| | | | | .. . .. . .. | | | | | | | | | | |
| | .. . .. | | | .. . .. . .. | | | | | | | | | | |
| | | | | .. . .. . .. | | | | | | | | | | |
| សរុបពិន្ទុប្រចាំត្រីមាស | | | | | | | | | | | | | | |

រាជធានីភ្នំពេញ ថ្ងៃទី        ខែ        ឆ្នាំ២០១...
**ប្រធាន គ.ស.ល នៃអគ្គនាយកដ្ឋាន......**
**អគ្គនាយក**

ឧបសម្ព័ន្ធ "១១.២" នៃសារាចរលេខ...០០៤... សហវ ចុះថ្ងៃទី..២៣ ខែកុម្ភៈ ឆ្នាំ២០១៧ ស្ដីពីការអនុវត្តប្រកាសលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ និងបទប្បញ្ញត្តិវិសោធនកម្មពាក់ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋាន..................**

## របាយការណ៍សមិទ្ធកម្មនៃការអនុវត្តផែនការសកម្មភាពសម្រាប់ទទួលប្រាក់ឧបត្ថម្ភមុខងារ ប្រចាំឆ្នាំ.......

**២. ផែនការសកម្មភាពក្រៅកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ:**

**២.១ គម្រោង...** *(ការងារសិក្សាស្រាវជ្រាវ/ការងាររៀបចំច្បាប់និងគោលនយោបាយ/ការងារជំនាញចាំបាច់/ការងារចូលរួមអនុវត្តគម្រោងនិងក្រុមការងារ/ការងារផ្ដល់មតិប្រឹក្សាច្បាប់)*

រយៈពេលអនុវត្ត÷.......ខែ ពី..... ដល់.....

| សកម្មភាព | គោលដៅសូចនាករឆ្នាំ | ទម្ងន់ | ខ្នាតរង្វាស់ | ត្រីមាសទី... | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ទម្ងន់ ១ | សូចនាករ ២ | គោលដៅ ៣ | លទ្ធផល ៤ | ពិន្ទុ ៥ | ពិន្ទុថ្លឹង ៦=៥x១ | អំណះអំណាង |
| សរុបទម្ងន់ | | ១ | | ១ | | | | | | |
| **២.១ គម្រោង...÷** *(គោលដៅនៃគម្រោង)...* ត្រូវបាន...។ | | | | | | | | | | |
| ២.១.១ | | | | | | | | | | |
| ២.១.២ | | | | | | | | | | |
| ២.១.៣ | | | | | | | | | | |
| ២.១.៤ | | | | | | | | | | |
| សរុបពិន្ទុប្រចាំត្រីមាស | | | | | | | | | | |

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១...
**អ្នករៀបចំតារាង**
**ប្រធាន.....**

**បានឃើញ និងឯកភាព**
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១...
**ប្រធាន គ.ស.ល នៃអគ្គនាយកដ្ឋាន......**
**អគ្គនាយក**

ឧបសម្ព័ន្ធ "ខ២.១" នៃសារាចរលេខ០០៤ សហវ ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការអនុវត្តប្រកាសលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ និងបទប្បញ្ញត្តិវិសោធនកម្មពាក់ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋាន....**

## របាយការណ៍សមិទ្ធកម្មនៃការអនុវត្តផែនការលើកទឹកចិត្ត ប្រចាំឆ្នាំ...

### I. សេចក្តីផ្តើម

- យន្តការនៃការផ្តល់ការលើកទឹកចិត្ត នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

### II. ផែនការលើកទឹកចិត្តប្រចាំឆ្នាំ....

- ចំនួនមន្ត្រីទទួលប្រាក់ឧបត្ថម្ភជីវភាព
- បរិយាយគម្រោង និងចំនួនមន្ត្រីទទួលប្រាក់ឧបត្ថម្ភមុខងារ

### III. វឌ្ឍនភាព

- ការបើកផ្តល់ប្រាក់ឧបត្ថម្ភជីវភាព
- វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពទទួលប្រាក់ឧបត្ថម្ភមុខងារ
- ប្រាក់ឧបត្ថម្ភមុខងារដែលទទួលបាន

### IV. បញ្ហាប្រឈម និងសំណើដំណោះស្រាយ

### V. សំណូមពរ

### VI. សន្និដ្ឋាន

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១...
**អ្នករៀបចំរបាយការណ៍**

**បានឃើញ និងឯកភាព**
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១...
**ប្រធាន គ.ស.ល នៃអគ្គនាយកដ្ឋាន......**
**អគ្គនាយក**

**ភ្ជាប់មកជាមួយ÷**
-របាយការណ៍សមិទ្ធកម្មនៃការអនុវត្តផែនការសកម្មភាពទទួលប្រាក់ឧបត្ថម្ភមុខងារប្រចាំឆ្នាំ...

ឧបសម្ព័ន្ធ "ខ២.២" នៃសារាចរលេខ០០៤...សហវ ចុះថ្ងៃទី១២ ខែកុម្ភៈ..ឆ្នាំ២០១៧ ស្តីពីការអនុវត្តប្រកាសលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ នឹងបទប្បញ្ញត្តិវិសោធនកម្មពាក់ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋាន..................**

## ឧបសម្ព័ន្ធ នៃរបាយការណ៍សមិទ្ធកម្មនៃការអនុវត្តផែនការលើកទឹកចិត្ត ប្រចាំឆ្នាំ...

## របាយការណ៍សមិទ្ធកម្មនៃការអនុវត្តផែនការសកម្មភាពសម្រាប់ទទួលប្រាក់ឧបត្ថម្ភមុខងារ

**១. ផែនការសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ:**

រយៈពេលអនុវត្ត÷.......ខែ ពី..... ដល់.....

| ផ្នែកគោលបំណង | ចង្កោមសកម្មភាព | | | សកម្មភាព | | | ពិន្ទុតាមត្រីមាស | | | | | លទ្ធផលឆ្នាំ | ពិន្ទុ | ពិន្ទុថ្លឹង | អំណះអំណាង |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | បរិយាយ | ទម្ងន CAP3 | ទម្ងន អង្គភាព | បរិយាយ | គោលដៅសូចនាករឆ្នាំ | ទម្ងន់ | តម១ | តម២ | តម៣ | តម៤ | មធ្យម | | | | |
| សរុបទម្ងន់ | | | ១ | | | ១ | | | | | | | | | |
| ផ្នែកទី១÷បន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា | | | | | | | | | | | | | | | |
| ក/បទី១១÷បន្តពង្រឹង..ចំណូល និង...ផែនការប្រមូលចំណូល | ១១.១ ពង្រឹង.... | | | ១១.១.១ | | | | | | | | | | | |
| | | | | ១១.១.២ | | | | | | | | | | | |
| | ១១.២ ... | | | ១១.២.១ | | | | | | | | | | | |
| | | | | ១១.២.២ | | | | | | | | | | | |
| ផ្នែកទី..÷ | | | | | | | | | | | | | | | |
| ក/បទី..÷ | .. . .. | | | .. . .. . .. | | | | | | | | | | | |
| | | | | .. . .. . .. | | | | | | | | | | | |
| | .. . .. | | | .. . .. . .. | | | | | | | | | | | |
| | | | | .. . .. . .. | | | | | | | | | | | |
| សរុបពិន្ទុប្រចាំត្រីមាស | | | | | | | | | | | | | | | |

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១...
**ប្រធាន គ.ស.ល នៃអគ្គនាយកដ្ឋាន......**
**អគ្គនាយក**

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១...
**អ្នករៀបចំតារាង**
**ប្រធាន.....**

ឧបសម្ព័ន្ធ "១២.៣" នៃសារាចរលេខ ០០៤ សហវ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការអនុវត្តប្រកាសលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ និងបទប្បញ្ញត្តិវិសោធនកម្មពាក់ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

## ឧបសម្ព័ន្ធ នៃរបាយការណ៍សមិទ្ធកម្មនៃការអនុវត្តផែនការលើកទឹកចិត្ត ប្រចាំឆ្នាំ...

## របាយការណ៍សមិទ្ធកម្មនៃការអនុវត្តផែនការសកម្មភាពសម្រាប់ទទួលប្រាក់ឧបត្ថម្ភមុខងារ

**២. ផែនការសកម្មភាពក្រៅកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ:**

**២.១ គម្រោង...** *(ការងារស្រាវជ្រាវ/ការងាររៀបចំឯកសារណែនាំ និងគោលនយោបាយ/ការងាររៀបចំច្បាប់ និងផ្តល់មតិប្រឹក្សាច្បាប់/ការងារចូលរួមក្រុមការងារ)*

រយៈពេលអនុវត្ត÷.......ខែ ពី..... ដល់.....

| សកម្មភាព | គោលដៅសូចនាករឆ្នាំ | ទម្ងន់ | ពិន្ទុតាមត្រីមាស | | | | | លទ្ធផលឆ្នាំ | ពិន្ទុ | ពិន្ទុថ្លឹង | អំណះអំណាង |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | តម១ | តម២ | តម៣ | តម៤ | មធ្យម | | | | |
| សរុបទម្ងន់ | | ១ | | | | | | | | | |
| **២.១ គម្រោង...÷** *(គោលដៅនៃគម្រោង)...* ត្រូវបាន...។ | | | | | | | | | | | |
| ២.១.១ | | | | | | | | | | | |
| ២.១.២ | | | | | | | | | | | |
| ២.១.៣ | | | | | | | | | | | |
| ២.១.៤ | | | | | | | | | | | |
| សរុបពិន្ទុប្រចាំត្រីមាស | | | | | | | | | | | |

**បានឃើញ និងឯកភាព**
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១...
**ប្រធាន គ.ស.ល នៃអគ្គនាយកដ្ឋាន......**
**អគ្គនាយក**

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១...
**អ្នករៀបចំតារាង**
**ប្រធាន.....**

ឧបសម្ព័ន្ធ "ខ៣" នៃសារាចរលេខ០០៤ សហវ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការអនុវត្តប្រកាសលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ និងបទប្បញ្ញត្តិវិសោធនកម្មពាក់ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋាន....**

## ការវាយតម្លៃសមិទ្ធកម្មមន្ត្រីទទួលបានប្រាក់ឧបត្ថម្ភជីវភាព
## ប្រចាំត្រីមាសទី.... ឆ្នាំ........

គោត្តនាម- នាមមន្ត្រី÷...............................................
មុខងារ÷..........................................................

## I. ការវាយតម្លៃសមិទ្ធកម្មមន្ត្រី

### ១. សមិទ្ធកម្មតាមមុខងារនិងភារកិច្ច (៤០%)

| ល.រ | លក្ខខណ្ឌការងារ | លទ្ធផលដែលសម្រេចបាន | មតិយោបល់ | ពិន្ទុ (១-១០០) |
|---|---|---|---|---|
| *បំពេញដោយមន្ត្រីអនុវត្ត* | | | *បំពេញដោយអ្នកគ្រប់គ្រងផ្ទាល់* | |
| ១ | | | | |
| ២ | | | | |
| ការងារបន្ថែម | | | | |
| | | | **សរុបពិន្ទុសមិទ្ធកម្មតាមមុខងារនិងភារកិច្ច** | |
| | | | **ពិន្ទុថ្លឹង (១) : ពិន្ទុសរុប x ៤០%** | |

### ២. វត្តមាន (៥០%)

| ល.រ | សមាសធាតុវាយតម្លៃ | ពិន្ទុ (១-១០០) | មូលហេតុ |
|---|---|---|---|
| | | *បំពេញដោយអ្នកគ្រប់គ្រងផ្ទាល់* | |
| ១ | វត្តមាន | | |
| ២ | មកយឺត ឬចេញមុន | | |
| | **សរុបពិន្ទុវត្តមាន** | | |
| | **ពិន្ទុថ្លឹង (២) : ពិន្ទុសរុប x ៥០%** | | |

### ៣. សមត្ថភាពអនុវត្តការងារ (១០%)

| ល.រ | សមាសធាតុវាយតម្លៃ | ពិន្ទុ (១-១០០) | មូលហេតុ |
|---|---|---|---|
| | | *បំពេញដោយអ្នកគ្រប់គ្រងផ្ទាល់* | |
| ១ | **ឥរិយាបថ និងវិន័យ** | | |
| | គោរពវិន័យការងារ ម៉ោងពេលធ្វើការ និងបទបញ្ជាផ្ទៃក្នុងរបស់អង្គភាព | | |
| | ស្មារតីទទួលខុសត្រូវ | | |
| | ការគោរពឋានុក្រមការងារ និងគោរពការសម្ងាត់វិជ្ជាជីវៈនិងកាតព្វកិច្ចលក្ខណការណ៍ | | |
| ២ | **សមត្ថភាពវិជ្ជាជីវៈ** | | |
| | សមត្ថភាពបំពេញការងារ | | |
| | អភិវឌ្ឍសមត្ថភាព ចំណេះដឹង និង ជំនាញ | | |
| | គំនិតផ្តួចផ្តើមនិងច្នៃប្រឌិត (កែលម្អសកម្មភាពការងារ ដើម្បីប្រសិទ្ធភាព និងជោគជ័យ) | | |
| ៣ | **ភាពជាអ្នកដឹកនាំ** | | |
| | សហការការងារជាមួយមន្ត្រីរាជការដទៃដើម្បី សម្រេចលទ្ធផលរួម/ស្មារតីជាក្រុម | | |

| | | | |
|---|---|---|---|
| | ទំនាក់ទំនងអន្តរបុគ្គល | | |
| | សមត្ថភាពអនុវត្តការងារក្រោមសម្ពាធ | | |
| | | សរុបពិន្ទុសមត្ថភាពអនុវត្តការងារ | |
| | | ពិន្ទុថ្លឹង (៣) : ពិន្ទុសរុប x ១០% | |
| | | **ពិន្ទុថ្លឹងសរុប= ពិន្ទុថ្លឹង (១) + ពិន្ទុថ្លឹង (២) + ពិន្ទុថ្លឹង (៣)** | |

**លំដាប់ពិន្ទុ÷ល្អណាស់ > ៩០ – ១០០ , ល្អ > ៨០ – ៩០ , ល្អបង្គួរ > ៧០ – ៨០ , មធ្យម > ៥០ – ៧០ , ខ្សោយ < ៥០**

## II. វិធានការលើកទឹកចិត្ត

អ្នកគ្រប់គ្រងផ្ទាល់ អាចជ្រើសរើសប្រភេទនៃការលើកទឹកចិត្តយ៉ាងច្រើន ៣ (បី) ដោយផ្អែកទៅតាមពិន្ទុនៃការវាយតម្លៃ ។

| | ☑ | មតិយោបល់បន្ថែម |
|---|---|---|
| | *បំពេញដោយអ្នកគ្រប់គ្រងផ្ទាល់* | |
| ១.ត្រៀមសម្រាប់ទទួលគ្រឿងឥស្សរិយយស | | |
| ២.ត្រៀមសម្រាប់ទទួលប័ណ្ណសរសើរក្រសួង | | |
| ៣.ត្រៀមសម្រាប់ទទួលការតែងតាំងកាន់មុខតំណែងខ្ពស់បន្ទាប់ | | |
| ៤.ត្រៀមសម្រាប់ទទួលប្រាក់រង្វាន់លើកទឹកចិត្ត | | |
| ៥.ត្រៀមសម្រាប់ទទួលការអភិវឌ្ឍសមត្ថភាព (ការបណ្តុះបណ្តាល ការបង្វឹក ផែនការអាជីព) | | |
| ៦.ត្រៀមឡើងថ្នាក់ (ស្វ័យប្រវត្តិ) | | |
| ៧.បណ្តុះបណ្តាល និងបង្កើនជំនាញបម្លែមរយៈពេលខ្លី | | |
| ៨.បណ្តុះបណ្តាល និងបង្កើនជំនាញបម្លែមរយៈពេលយូរ | | |
| ៩.បង្អាក់ការឡើងថ្នាក់ | | |
| ១០.វិធានការរដ្ឋបាលតាមករណីចាំបាច់ | | |

**សម្រេច ÷ បន្ត☐ បញ្ឈប់☐**

មតិយោបល់របស់មន្ត្រីអនុវត្ត÷......................................

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១...
**អ្នកគ្រប់គ្រងផ្ទាល់**

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១...
**មន្ត្រី**

ក្នុងករណីមិនមានការឯកភាពលើការវាយតម្លៃ

| | ឈ្មោះ | តួនាទី | កាលបរិច្ឆេទ | ហត្ថលេខា | មតិយោបល់ |
|---|---|---|---|---|---|
| មន្ត្រីអនុវត្ត | | | | | |
| អ្នកវាយតម្លៃ ឬអ្នកគ្រប់គ្រងផ្ទាល់ | | | | | |
| សម្រេចដោយអ្នកគ្រប់គ្រងខ្ពស់បន្ទាប់ | | | | | |

**បានឃើញ និងឯកភាព**
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១...
**ប្រធាន គ.ស.ល នៃអគ្គនាយកដ្ឋាន......**
**អគ្គនាយក**

ឧបសម្ព័ន្ធ "ខ៤" នៃសារាចរលេខ០០៤ សហវ ចុះថ្ងៃទី០៧ខែកុម្ភៈ ឆ្នាំ២០១៧ ស្ដីពីការអនុវត្តប្រកាសលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ និងបទប្បញ្ញត្តិវិសោធនកម្មពាក់ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គនាយកដ្ឋាន....**

## របាយការណ៍វាយតម្លៃសមិទ្ធកម្មមន្ត្រីទទួលបានប្រាក់ឧបត្ថម្ភមុខងារ ប្រចាំត្រីមាសទី.... ឆ្នាំ....

**I. ផែនការសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ/ក្រៅការងារកែទម្រង់**

**១. គម្រោង/ក្រុមការងារ...**

| ល.រ | គោត្តនាម នាម | ភេទ | មុខតំណែង | មុខងារក្នុងក្រុមការងារ | ភារកិច្ចនិងការទទួលខុសត្រូវ | សមិទ្ធកម្ម | និទ្ទេស |
|---|---|---|---|---|---|---|---|
| ១. | | | | ប្រធានក្រុមការងារ | • ទទួលបន្ទុក | • | |
| ២. | | | | អនុប្រធានក្រុមការងារ | • ទទួលបន្ទុក | • | |
| ៣. | | | | សមាជិក | • ទទួលបន្ទុក | • | |

កំណត់សម្គាល់÷ និទ្ទេសមាន÷ ល្អណាស់, ល្អ, ល្អបង្គួរ, មធ្យម និងខ្សោយ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១...

**....... (មុខតំណែង) និងជាប្រធានគម្រោង/ក្រុមការងារ**

បានឃើញ និងឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១...

**ប្រធាន គ.ស.ល នៃអគ្គនាយកដ្ឋាន......**

**អគ្គនាយក**

ឧបសម្ព័ន្ធ "ខ៥" នៃសារាចរលេខ០០៤ សហវ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការអនុវត្តប្រកាសលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ និងបទប្បញ្ញត្តិវិសោធនកម្មពាក់ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋាន....**

## របាយការណ៍វាយតម្លៃសមិទ្ធកម្មមន្ត្រីទទួលបានប្រាក់ឧបត្ថម្ភជីវភាព ប្រចាំត្រីមាសទី.... ឆ្នាំ........

| ល.រ | គោត្តនាម នាម | ភេទ | មុខតំណែង | សន្ទស្សន៍ | ពិន្ទុ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១. | | | | | | | | | | | | | | | |
| ២. | | | | | | | | | | | | | | | |
| ៣. | | | | | | | | | | | | | | | |
| ៤. | | | | | | | | | | | | | | | |
| ៥. | | | | | | | | | | | | | | | |
| ៦. | | | | | | | | | | | | | | | |

កំណត់សម្គាល់÷ មធ្យមពិន្ទុលើសពី ៥០ ទើបអាចទទួលបានប្រាក់ឧបត្ថម្ភជីវភាព

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១...
**អ្នករៀបចំតារាង**

**បានឃើញ និងឯកភាព**
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១...
**ប្រធាន គ.ស.ល នៃអគ្គនាយកដ្ឋាន......**
**អគ្គនាយក**

១.ត្រៀមសម្រាប់ទទួលគ្រឿងឥស្សរិយយស
២.ត្រៀមសម្រាប់ទទួលប័ណ្ណសរសើរក្រសួង
៣.ត្រៀមសម្រាប់ទទួលការតែងតាំងកាន់មុខតំណែងខ្ពស់បន្ទាប់
៤.ត្រៀមសម្រាប់ទទួលប្រាក់រង្វាន់លើកទឹកចិត្ត
៥.ត្រៀមសម្រាប់ទទួលការអភិវឌ្ឍសមត្ថភាព (ការបណ្តុះបណ្តាល ការបង្វឹក ផែនការអាជីព)
៦.ត្រៀមឡើងថ្នាក់ (ស្វ័យប្រវត្តិ)
៧.បណ្តុះបណ្តាល និងបង្កើនជំនាញបម្លែមរយៈពេលខ្លី
៨.បណ្តុះបណ្តាល និងបង្កើនជំនាញបម្លែមរយៈពេលយូរ
៩.បង្អកការឡើងថ្នាក់
១០.វិធានការរដ្ឋបាលតាមករណីចាំបាច់

ឧបសម្ព័ន្ធ "ខ៦" នៃសារាចរលេខ០០៤ សហវ ចុះថ្ងៃទី០២ខែតុលា ឆ្នាំ២០១៧ ស្តីពីការអនុវត្តប្រកាសលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ និងបទប្បញ្ញត្តិវិសោធនកម្មពាក់ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋាន..................**

**បញ្ជីសម្រង់អវត្តមានមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា និងការផ្លាស់ប្តូរស្ថានភាពរដ្ឋបាល ប្រចាំខែ... ឆ្នាំ...**

| ល.រ | គោត្តនាម នាម | ភេទ | តួនាទី | ចំនួនសរុបនៃអវត្តមាន | មូលហេតុអវត្តមាន | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ឥតច្បាប់ | មានច្បាប់ | | | | | បេសកកម្ម | សុំឈប់ ឬស្លាប់ ឬផ្លាស់ចេញ(ថ្ងៃខែឆ្នាំ) | ផ្សេងៗ (ក្រៅក្រ.ខដើម/ទំនេរគ្មានបៀ.) |
| | | | | | | រយៈពេលខ្លី | ប្រចាំឆ្នាំ | មាតុភាព | ព្យាបាលជម្ងឺ | កិច្ចការផ្ទាល់ខ្លួន | | | |
| | | | | គិតជាថ្ងៃ | | | | គិតជាខែ | | | គិតជាថ្ងៃ | | |
| ១ | | | | | | | | | | | | .../.../..... | .../.../..... |
| ២ | | | | | | | | | | | | .../.../..... | .../.../..... |
| ៣ | | | | | | | | | | | | .../.../..... | .../.../..... |
| ៤ | | | | | | | | | | | | .../.../..... | .../.../..... |
| ៥ | | | | | | | | | | | | .../.../..... | .../.../..... |
| ៦ | | | | | | | | | | | | .../.../..... | .../.../..... |
| ៧ | | | | | | | | | | | | .../.../..... | .../.../..... |

<u>*កំណត់សម្គាល់*</u>÷បញ្ជីស្នើសុំកែសម្រួលការបើកប្រាក់ឧបត្ថម្ភ ត្រូវបញ្ជូនមកនាយកដ្ឋានបុគ្គលិក នៃអគ្គលេខាធិការដ្ឋានក្នុងសប្តាហ៍ទី១ នៃខែបន្ទាប់។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១...
**អ្នករៀបចំតារាង**

**បានឃើញ និងឯកភាព**
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១...
**ប្រធាន គ.ស.ល នៃអគ្គនាយកដ្ឋាន......**
**អគ្គនាយក**

ឧបសម្ព័ន្ធ "ខ៧" នៃសារាចរលេខ.០០៤.សហវ ចុះថ្ងៃទី១២ ខែ.[illegible]. ឆ្នាំ២០១៧ ស្តីពីការអនុវត្តប្រកាសលេខ ៦១៦ សហវ.ប្រក

ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ នឹងបទប្បញ្ញត្តិវិសោធនកម្មពាក់ព័ន្ធ

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គនាយកដ្ឋាន..................**

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**បញ្ជីសម្រង់បម្រែបម្រួលសមាសភាពមន្ត្រីទទួលប្រាក់ឧបត្ថម្ភ ប្រចាំខែ.... ឆ្នាំ....**

## I. ប្រាក់ឧបត្ថម្ភជីវភាព

| ល.រ | គោត្តនាម នាម | ភេទ | តួនាទី | បរិយាយមូលហេតុ/ឯកសារយោង | សន្ទស្សន៍ | ប្រាក់ឧបត្ថម្ភប្រចាំខែ | ប្រាក់ឧបត្ថម្ភប្រចាំឆ្នាំ | ធនាគារ | លេខគណនី |
|---|---|---|---|---|---|---|---|---|---|
| ១ | | | | | | | | | |
| ២ | | | | | | | | | |
| សរុបប្រាក់ឧបត្ថម្ភជីវភាព | | | | | | | | | |

## II. ប្រាក់ឧបត្ថម្ភមុខងារ

| ល.រ | គោត្តនាម នាម | ភេទ | តួនាទី | បរិយាយមូលហេតុ/ឯកសារយោង | សន្ទស្សន៍ | ប្រាក់ឧបត្ថម្ភប្រចាំខែ | ប្រាក់ឧបត្ថម្ភប្រចាំឆ្នាំ | ធនាគារ | លេខគណនី |
|---|---|---|---|---|---|---|---|---|---|
| **១.ផែនការសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** | | | | | | | | | |
| ១ | | | | | | | | | |
| ២ | | | | | | | | | |
| **២.ផែនការសកម្មភាពក្រៅការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** | | | | | | | | | |
| **២.១.គម្រោង** | | | | | | | | | |
| ៣ | | | | | | | | | |
| ៤ | | | | | | | | | |
| សរុបប្រាក់ឧបត្ថម្ភមុខងារ | | | | | | | | | |

**បានឃើញ និងឯកភាព**

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១...

**ប្រធាន គ.ស.ល នៃអគ្គនាយកដ្ឋាន......**

**អគ្គនាយក**

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១...

**អ្នករៀបចំតារាង**

ឧបសម្ព័ន្ធ "គ១" នៃសារាចរលេខ.០០៤.សហវ ចុះថ្ងៃទី.០២ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការអនុវត្តប្រកាសលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ និងបទប្បញ្ញត្តិវិសោធនកម្មពាក់ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**គណៈកម្មាធិការវាយតម្លៃសមិទ្ធកម្មនិងផ្តល់ការលើកទឹកចិត្ត**

# ការត្រួតពិនិត្យនិងវាយតម្លៃសមិទ្ធកម្មសម្រាប់ប្រាក់ឧបត្ថម្ភមុខងារ

អង្គភាព : ........................................ អ្នកត្រួតពិនិត្យ : ....................

គម្រោង : ........................................ មុខតំណែង : ....................

មុខងារ : ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រីមាសទី : ....... ឆ្នាំ : ............. កាលបរិច្ឆេទ : ....................

វិធីសាស្ត្រត្រួតពិនិត្យនិងវាយតម្លៃ : ☐ ពិនិត្យរបាយការណ៍សមិទ្ធកម្ម ☐ កិច្ចប្រជុំពិភាក្សាជាមួយអង្គភាពសាមី ថ្ងៃទី...............................

| លេខសកម្មភាព | សូចនាករ | ទម្ងន់ | ខ្នាត | គោលដៅត្រីមាស | លទ្ធផល | ពិន្ទុរាយការណ៍ | ត្រឹមត្រូវ ឬពុំត្រឹមត្រូវ | មូលហេតុពុំត្រឹមត្រូវ | ពិន្ទុគួរទទួលបាន | ពិន្ទុថ្លឹង |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | សរុប | |

បានឃើញនិងឯកភាព
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១..
**អគ្គលេខាធិការ**
**អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១..
**អ្នកត្រួតពិនិត្យនិងវាយតម្លៃ**

ឧបសម្ព័ន្ធ "គ២" នៃសារាចរលេខ០០៤សហវ ចុះថ្ងៃទី០២ខែកុម្ភៈឆ្នាំ២០១៧ ស្ដីពីការអនុវត្តប្រកាសលេខ ៦១៦ សហវ.ប្រក
ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ និងបទប្បញ្ញត្តិវិសោធនកម្មពាក់ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**គណៈកម្មាធិការវាយតម្លៃសមិទ្ធកម្មនិងផ្ដល់ការលើកទឹកចិត្ត**

## ការត្រួតពិនិត្យនិងវាយតម្លៃសមិទ្ធកម្មសម្រាប់ថ្នាក់ឧបត្ថម្ភមុខងារ

អង្គភាព : ............................................................ អ្នកត្រួតពិនិត្យ : ..............................
គម្រោង : ............................................................ មុខតំណែង : ..............................
មុខងារ : ការងារក្រោកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រីមាសទី : ........ ឆ្នាំ : .............. កាលបរិច្ឆេទ : ..............................
វិធីសាស្ត្រត្រួតពិនិត្យនិងវាយតម្លៃ : ☐ ពិនិត្យរបាយការណ៍សមិទ្ធកម្ម ☐ កិច្ចប្រជុំពិភាក្សាជាមួយអង្គភាពសាមី ថ្ងៃទី..................................

| លេខសកម្មភាព | សូចនាករ | ទម្ងន់ | ខ្នាត | គោលដៅត្រីមាស | លទ្ធផល | ពិន្ទុរាយការណ៍ | ត្រឹមត្រូវឬពុំត្រឹមត្រូវ | មូលហេតុពុំត្រឹមត្រូវ | ពិន្ទុគួរទទួលបាន | ពិន្ទុថ្លឹង |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | សរុប | |

បានឃើញនិងឯកភាព
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១..
**អគ្គលេខាធិការ**
**អគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១..
**អ្នកត្រួតពិនិត្យនិងវាយតម្លៃ**

ឧបសម្ព័ន្ធ "ង១.១" នៃសារាចរលេខ០០៤ សហវ ចុះថ្ងៃទី២៧ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការអនុវត្តប្រកាសលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ និងបទប្បញ្ញត្តិវិសោធនកម្មពាក់ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានរតនាគារជាតិ**

## របាយការណ៍សមតុល្យគណនីប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រចាំខែ............ឆ្នាំ២០១...

ឯកតា÷ រៀល

| ផ្នែកចំណូល | | | ផ្នែកចំណាយ | | សមតុល្យចុងគ្រា | ផ្សេងៗ |
|---|---|---|---|---|---|---|
| ប្រភពចំណូល | សមតុល្យដើមគ្រា (១) | ចំណូលក្នុងខែ (២) | បរិយាយចំណាយ | ចំណាយក្នុងខែ (៣) | (៤=១+២-៣) | |
| **សរុប** | | | | | | |
| ១. អគ្គនាយកដ្ឋាន... | | | ១. ប្រាក់ឧបត្ថម្ភជីវភាព | | | |
| ២. | | | ២. ប្រាក់ឧបត្ថម្ភមុខងារ | | | |
| ៣. | | | ៣. ... | | | |

រាជធានីភ្នំពេញ ថ្ងៃទី......ខែ...........ឆ្នាំ២០១....
**អ្នកធ្វើតារាង**

**បានឃើញ និងឯកភាព**
រាជធានីភ្នំពេញ ថ្ងៃទី......ខែ...........ឆ្នាំ២០១....
**អគ្គនាយក**
**អគ្គនាយកដ្ឋានរតនាគារជាតិ**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានរតនាគារជាតិ

ឧបសម្ព័ន្ធ "ង១.២" នៃសារាចរលេខ០០៤ សហវ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧ ស្ដីពីការអនុវត្តប្រកាសលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ និងបទប្បញ្ញត្តិវិសោធនកម្មពាក់ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**របាយការណ៍សមតុល្យគណនីប្រាក់រៀវទ្ធានរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រចាំត្រីមាសទី.....ឆ្នាំ២០១...**

ឯកតា÷ រៀល

| ផ្នែកចំណូល | | | | | | ផ្នែកចំណាយ | | | | | សមតុល្យចុងគ្រា | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រភពចំណូល | សមតុល្យដើមគ្រា | ចំណូលក្នុងត្រីមាស (២) | | | | បរិយាយចំណាយ | ចំណាយក្នុងត្រីមាស (៣) | | | | | |
| | (១) | ខែ... | ខែ... | ខែ... | សរុបត្រីមាស | | ខែ... | ខែ... | ខែ... | សរុបត្រីមាស | (៤=១+២-៣) | |
| **សរុប** | | | | | | | | | | | | |
| ១. អគ្គនាយកដ្ឋាន... | | | | | | ១. ប្រាក់ឧបត្ថម្ភជីវភាព | | | | | | |
| ២. | | | | | | ២. ប្រាក់ឧបត្ថម្ភមុខងារ | | | | | | |
| ៣. | | | | | | ៣. ... | | | | | | |

រាជធានីភ្នំពេញ ថ្ងៃទី......ខែ............ឆ្នាំ២០១....
**អ្នកធ្វើតារាង**

**បានឃើញ និងឯកភាព**
រាជធានីភ្នំពេញ ថ្ងៃទី......ខែ............ឆ្នាំ២០១....
**អគ្គនាយក**
**អគ្គនាយកដ្ឋានរតនាគារជាតិ**

ឧបសម្ព័ន្ធ "ង១.៣" នៃសារាចរលេខ០០៤ សហវ ចុះថ្ងៃទី២២ ខែ[illegible] ឆ្នាំ២០១៧ ស្តីពីការអនុវត្តប្រកាសលេខ ៦១៦ សហវ.ប្រក
ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ និងបទប្បញ្ញត្តិវិសោធនកម្មពាក់ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានរតនាគារជាតិ**

## របាយការណ៍សមតុល្យគណនីប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រចាំឆ្នាំ២០១...

ឯកតា÷ រៀល

| ផ្នែកចំណូល | | | ផ្នែកចំណាយ | | សមតុល្យចុងគ្រា | ផ្សេងៗ |
|---|---|---|---|---|---|---|
| ប្រភពចំណូល | សមតុល្យដើមគ្រា (១) | ចំណូលក្នុងឆ្នាំ (២) | បរិយាយចំណាយ | ចំណាយក្នុងឆ្នាំ (៣) | (៤=១+២-៣) | |
| **សរុប** | | | | | | |
| ១. អគ្គនាយកដ្ឋាន... | | | ១. ប្រាក់ឧបត្ថម្ភជីវភាព | | | |
| ២. | | | ២. ប្រាក់ឧបត្ថម្ភមុខងារ | | | |
| ៣. | | | ៣. ... | | | |

រាជធានីភ្នំពេញ ថ្ងៃទី......ខែ...........ឆ្នាំ២០១....
**អ្នកធ្វើតារាង**

**បានឃើញ និងឯកភាព**
រាជធានីភ្នំពេញ ថ្ងៃទី......ខែ...........ឆ្នាំ២០១....
**អគ្គនាយក**
**អគ្គនាយកដ្ឋានរតនាគារជាតិ**